# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសក្រុមហ៊ុន ឬនីតិបុគ្គលវាយតម្លៃបញ្ចប់ការអនុវត្តគម្រោង
## *"ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញ ដើម្បីលើកកំពស់ជីវភាពរបស់សហគមន៍ជនជាតិដើមភាគតិច នៅក្បាលរមាស"*

អង្គការជនជាតិដើមភាគតិចកម្ពុជា ហៅកាត់ថា អ.ជ.ក បាននិងកំពុងអនុវត្តន៍គម្រោង *"ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញដើម្បីលើកកំពស់ជីវភាពរបស់សហគមន៍ជនជាតិដើមភាគតិច នៅក្បាលរមាស"* តាមរយៈការអភិវឌ្ឍន៍សហគម ន៍ គាំទ្រមូលនិធិពី UNDP-GEF-SGP ប្រចាំប្រទេសកម្ពុជានៃគម្រោង លេខ KHM/SGP/OP6/Y5/CORE/IPAE/2020/01 រយៈពេល១៨ខែ ចាប់ពីខែធ្នូ ឆ្នាំ២០២០ រហូតដល់ខែមេសា ឆ្នាំ២០២២។ គម្រោងនេះ អនុវត្តជាមួយសហគមន៍ ជនជាតិដើមភាគតិចព្នងភូមិក្បាលរមាស ស្ថិតក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង។

គម្រោងបានអនុវត្តបាន១៧ខែកន្លងមក ហើយនិងបញ្ចប់នៅក្នុងខែមេសា ឆ្នាំ២០២២ខាងមុខ គម្រោងធ្វើការជ្រើស រើសក្រុមហ៊ុន ឬនីតិបុគ្គល វាយតម្លៃបញ្ចប់គម្រោង ក្នុងគោលបំណង អ្នកវាយ តម្លៃឯករាជ្យ នឹងត្រូវធ្វើការវាយតម្លៃទៅលើ ប្រសិទ្ធភាពនិងឥទ្ធិពលដែលស្តែងចេញពីការអនុវត្ត សកម្មភាព នានារបស់គម្រោង កត់ត្រាបទពិសោធន៍ល្អៗ មេរៀនដែល ទទួលបានពីការអនុវត្តគម្រោងនិង ផ្តល់ជាអនុសាសន៍នានាសម្រាប់ជាគោលគំនិតក្នុងការរៀបចំគម្រោង ដើម្បីទុកអនុវត្ត ពេលក្រោយៗទៀត។

អាស្រ័យហេតុនេះ សូមក្រុមហ៊ុន ឬនីតិបុគ្គល មានបទពិសោធន៍ខាងវាយ តម្លៃបញ្ចប់គម្រោង ដែលមានចំណាប់ អារម្មណ៍ផ្តល់សេវានេះ សូមផ្ញើរលិខិតចំណាប់អាម្មណ៍ បូករួមគម្រោងសង្ខេប នៃការការវាយ តម្លៃ និងប្រវត្តិរូប មកការិយាល័យ អង្គការជនជាតិដើមភាគតិចកម្ពុជា យើងខ្ញុំតាមអាសយដ្ឋាន ផ្ទះលេខ២៨ ផ្លូវលេខ ៤៦០ ភូមិ៤ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា លេខទំនាក់ទំនង : ០១២ ៥៧១ ៦៣៦ ឬ តាមរយៈអ៊ីម៉ែល info@cipocambodia.org អោយបានមុនម៉ោង ៥ ល្ងាចថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២២។ *ដូចមានចែងក្នុងតួនាទីនិងការ ទទួលខុសត្រូវមកជាមួយ។*

ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកមន្ត្រីគម្រោង តាមរយៈទូរស័ព្ទលេខ ០៩២ ៩៩៨ ៤៧០ /០១០ ៩៥៩ ៨២៥ រៀងរាល់ម៉ោងធ្វើការ។

សូមអរគុណ!

# លក្ខខ័ណ្ឌ ការងារការវាយតម្លៃគម្រោង

## ១. ពណ៌នាអំពីប្រវត្តិគម្រោង៖

អង្គការជនជាតិដើមភាគតិចកម្ពុជាហៅកាត់ថា អ.ជ.ក ជាអង្គការមិនមែនរដ្ឋាភិបាលមួយនៅព្រះរាជាណាចក្រកម្ពុជា ដែលបានចុះបញ្ជីនិងទទួល ស្គាល់ជាផ្លូវការដោយក្រសួងមហាផ្ទៃ តាមលិខិតលេខ១៣៥៣ស.ជ.ណចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៤។ អង្គការ អ.ជ.ក បាននឹងកំពុងអនុវត្ត សកម្មភាពជាច្រើនដើម្បីសម្រេចគោលដៅដែលធានាថាធនធានធម្មជាតិត្រូវបានថែរក្សា និងការពារប្រកបដោយសមធម៌សម្រាប់ការប្រើប្រាស់ និងជីវភាពរស់នៅប្រកបដោយនិរន្តរភាពរបស់ប្រជាជន នាពេលបច្ចុប្បន្ន និងជំនាន់ក្រោយៗ ទៀត ដែល នឹងរួមចំណែកដល់អត្ថប្រយោជន៍នៃការអភិវឌ្ឍប្រទេសជាតិប្រកប ដោយចីរភាពនិងការកាត់បន្ថយភាពក្រីក្រ។ គោលបំណង សកម្មភាពនិងយុទ្ធសាស្ត្រទាំងអស់របស់អង្គការ អ.ជ.ក មានបំណងបម្រើ ផលប្រយោជន៍សាធារណៈ សង្គមស៊ីវិល និងប្រជាជនកម្ពុជាទាំងអស់។ អង្គការអ.ជ.ក មានបទពិសោធន៍ យូរអង្វែង ជាមួយការថែរក្សាបរិស្ថាន ការអភិរក្ស និងការគ្រប់គ្រងធនធានធម្មជាតិ ចាប់តាំងពីឆ្នាំ២០១៤ អង្គការបានពង្រីកសកម្មភាពដល់ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគីរី និងខេត្តរតនគិរី ដើម្បីអនុវត្តកម្មវិធីបន្សាំ នឹងការ ប្រែប្រួលអាកាសធាតុនិងកម្មវិធីកាត់ បន្ថយហានិភ័យគ្រោះមហន្តរាយដោយមានការសម្របសម្រួលល្អពី គ្រប់ភាគី ពាក់ព័ន្ធទាំងអស់ដែលនាំឲ្យអង្គការ អ.ជ.ក សំរេចបានជោគជ័យ នូវសកម្មភាពគ្រោងទុកប្រកបដោយ គុណភាព និង ប្រសិទ្ធភាពខ្ពស់ ដើម្បីបំពេញតាមតម្រូវការរបស់ សហគមន៍ មូលដ្ឋានសម្រាប់ ការគ្រប់គ្រងធនធាន ធម្មជាតិ និងការកាត់បន្ថយភាពក្រីក្រ។

អង្គការ អ.ជ.ក បានទទួលថវិកាពីអង្គការ UNDP GEF SGP ប្រចាំប្រទេសកម្ពុជា នៃគម្រោងលេខ KHM/SGP/OP6/Y5/CORE/IPAE/2020/01 ដើម្បីអនុវត្តន៍កម្មវិធី ដែលមានឈ្មោះថា ***"ជំរុញការប្រើប្រាស់ថាមពលកកើតឡើងវិញដើម្បីលើកកំពស់ជីវភាពរបស់សហគមន៍ជនជាតិដើមភាគតិចនៅក្បាលរមាស"*** គម្រោងនេះ អនុវត្តជាមួយ សហគមន៍ ជនជាតិដើមភាគតិចក្នុងភូមិក្បាលរមាស ស្ថិតក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង។

បច្ចុប្បន្នអង្គការ អ.ជ.ក បានអនុវត្តន៍គម្រោងដោយបានសហការជាមួយ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តស្ទឹងត្រែង និងអាជ្ញាធរមូលដ្ឋានបានកំពុង និងអនុវត្តនូវកម្មវិធីរបស់ខ្លួនបានរយៈពេល ១៨ ខែដោយគិតចាប់ពី ខែធ្នូ ឆ្នាំ២០២០ ដល់ខែមីនា ២០២២។

## ២. គោលដៅជាក់លាក់របស់គម្រោង៖

សមាជិកសហគមន៍ និងប្រជាពលរដ្ឋ ពិសេសជនជាតិដើមភាគតិច បង្កើនបាននូវប្រាក់ចំណូល ព្រមទាំងសមត្ថភាពក្នុងការគ្រប់គ្រងធនធានព្រៃឈើ តាមរយៈការអភិវឌ្ឍសហគមន៍ទេសចរណ៍ធម្មជាតិ ដើម្បី លើកស្ទួយជីវភាពសហគមន៍ ចូលរួមការពារប្រព័ន្ធអេឡូស៊ី និងកាត់បន្ថយការដាក់សម្ពាធលើធនធានធម្មជាតិ។

**<u>គោលបំណងជាក់លាក់នីមួយៗ៖</u>**

**គោលបំណងទី១៖** នៅត្រឹមបំណាច់ខែសីហា ឆ្នាំ២០២២ ជនជាតិដើមភាគតិចព្នងចំនួន ៥២គ្រួសារ ស្មើនឹង ២២១នាក់ ក្នុងនោះស្ត្រី ១២៦ នៅភូមិក្បាលរមាស ឃុំសេសាន ស្រុកសេសាន ខេត្តស្ទឹងត្រែង នឹងមានភ្លើងអគ្គិសនី ដើរដោយ ថាមពល ព្រះអាទិត្យសម្រាប់ការប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃដើម្បីបំភ្លឺគេហដ្ឋាន ប្រើកង្ហារ សាក់ទូរស័ព្ទជាដើម និងមានទឹកស្អាត ដែលអាចមកជិតផ្ទះ សម្រួលដល់ការរស់នៅប្រចាំថ្ងៃ សុខភាពល្អ និងបង្កើនកំរិតជីវភាពប្រសើរជាងមុន ជាពិសេស ដល់ ក្រុមស្ត្រីនិងកុមារ។

**គោលបំណងទី២៖** នៅត្រឹមបំណាច់ខែសីហា ឆ្នាំ២០២២ ជនជាតិដើមភាគតិចព្នងចំនួន ៥២គ្រួសារ ស្មើនឹង ២២១នាក់ ក្នុងនោះស្ត្រី ១២៦ នៅភូមិក្បាលរមាស ឃុំសេសាន ស្រុកសេសាន ខេត្តស្ទឹងត្រែង នឹងមាន បណ្តាញតទឹកស្អាតដល់ភូមិដ្ឋានឬដល់គេហដ្ឋានរបស់ពួកគេផ្ទាល់ដោយសារការតបណ្តាញនិងការទាញទឹកស្អាតចូលក្នុងស្ថានីយទឹកស្អាតដើរដោយភ្លើងអគ្គិសនីផ្ទាំងសូឡារដើរដោយថាមពលព្រះអាទិត្យសម្រាប់ការប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃសម្រួលដល់ការទៅដងទឹកដែលមានចម្ងាយពី២ទៅ៥គីឡូម៉ែត្រពីភូមិរបស់ស្ត្រីនិងកុមារតូចៗ។

**<u>៣. វិធីសាស្ត្រអនុវត្តសកម្មភាព៖</u>**

- ដើម្បីបង្ហាញពីឯករាជ្យភាពនិងតម្លាភាពតម្រូវអោយទីប្រឹក្សា ប្រើឧបករណ៍វាយតំលៃដែលមានការចូលរួមពីអ្នកពាក់ព័ន្ធដើម្បីត្រួតពិនិត្យនិងយល់ព្រម ។
- ពេលវេលា៖ បង្កើតកាលវិភាគនិងសកម្មភាពសំរាប់រយៈពេលចុះធ្វើការវាយតំលៃ។
- ការវិភាគព័ត៌មាន៖ ឧបករណ៍វាស់វែងសមត្ថភាពក្រុម និងការឆ្លុះបញ្ចាំងជាមួយសហគមន៍ អំពីចំណុចវិជ្ជមាន អវិជ្ជមានក៏ដូចជាចំណុចចាប់អារម្មណ៍ដែល នឹងត្រូវប្រើប្រាស់សំរាប់ការវិភាគ ព័ត៌មានបែបគុណភាព។ ឧបករណ៍ផ្សេងៗអាចត្រូវបានប្រើនៅក្នុងការវាយតំលៃនេះដោយមាន ការពិភាក្សាជាមួយសហគមន៍គោលដៅ អ្នកទទួលផលពីគម្រោង និងអ្នកអនុវត្តគម្រោង នឹងចូលរួមនៅក្នុងការផ្តល់នូវសេចក្តីសន្និដ្ឋាន និងអនុសាសន៍ ។

**<u>៤.តួនាទី៖</u>**

- ធ្វើការប្រមូលនិងពិនិត្យលើឯកសារពាក់ព័ន្ធដែលផ្តល់ដោយសាមីអង្គការនៃជំនួយ UNDP GEF SGP។
- រៀបចំដំណើរការវាយតំលៃរួមមាន ចុះសម្ភាសន៍ រៀបចំក្រុមពិភាក្សាជាមួយអ្នកពាក់ព័ន្ធគម្រោង (អាជ្ញាធរភូមិឃុំ ដែលពាក់ព័ន្ធ មន្ទីរជំនាញ ម្ចាស់ជំនួយ) និងសហគមន៍នៅតំបន់គោលដៅ។
- ធ្វើរបាយការណ៍វាយតំលៃគម្រោងអំពីដំណើរការនៃការវាយតំលៃរបកគម្ហើញនានា ផ្តល់បទពិសោធន៍ដែលអាចរៀនសូត្របានក្នុងអំឡុងពេលអនុវត្តគម្រោង និងការផ្តល់អនុសាសន៍ក្នុងការកែលំអ។
- របាយការណ៍វាយតំលៃគម្រោងជាភាសាខ្មែរ និងភាសាអង់គ្លេស ត្រូវរៀបចំដោយអ្នកវាយតំលៃ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ អ្នកទទួលផលសហគមន៍ ។

- រៀបចំធ្វើបទបង្ហាញ និងពន្យល់ពីរបកគម្ហើញនៃការវាយតំលៃតាមការស្នើសុំរបស់គម្រោងដែលបានរៀបចំរួចទៅអង្គការ និងអ្នកគ្រប់គ្រងរបស់អង្គការដើម្បីផ្តល់យោបល់ និងអនុសាសន៍លើរបាយការណ៍វាយតំលៃ ។
- ដាក់បញ្ចូលយោបល់ទាំងអស់ក្នុងរបាយការណ៍ចុងក្រោយទាំងភាសារខ្មែរ និងភាសាអង់គ្លេស ។

## ៥. វិសាលភាពការងារៈ

ក. សហគមន៍ជនជាតិដើមភាគតិចជាតំបន់គោលដៅ គឺសហគមន៍ជនជាតិដើមភាគតិចព្នងភូមិក្បាលរមាស ស្ថិតក្នុងភូមិក្បាលរមាស ឃុំក្បាលរមាស ស្រុកសេសាន ខេត្តស្ទឹងត្រែង។

## ៦.ក្រុមការងារពិសេសរបស់គម្រោងៈ

| លរ | គោត្តនាម និងនាម | តួនាទី | ការទទួលខុសត្រូវ |
|---|---|---|---|
| ១ | លោកស្រី យុន ម៉ាណេ | នាយិកាប្រតិបត្តិ | អ្នកទទួលខុសត្រូវគម្រោង |
| ២ | លោក ភាព សុជា | ប្រធានកម្មវិធី | អ្នកគ្រប់គ្រងគម្រោង |
| ៣ | លោក អៀវ ដារ៉ូ | មន្ត្រីគម្រោង | អ្នកអនុវត្តគម្រោង |

## ៧.ថវិកាៈ

ថវិកាចំនួន ១.៥០០,០០ (មួយពាន់ប្រាំរយដុល្លារអាមេរិកគត់)។

## ៨.លក្ខណៈសម្បត្តិនៃទីប្រឹក្សា

\+ **ការសិក្សាៈ** បញ្ចប់ថ្នាក់បរិញ្ញាបត្រ ឬបរិញ្ញាបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងគម្រោង បរិស្ថាន ការសិក្សាផ្នែកអភិវឌ្ឍន៍ ឬកសិកម្ម

\+ **បទពិសោធន៍ៈ**

- មានបទពិសោធន៍យ៉ាងតិច ៥ឆ្នាំទាក់ទងនិងការវាយតម្លៃគម្រោងលើផ្នែក ការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍន៍ជនបទ គម្រោងថាមពលស្អាត និងទឹកស្អាត។
- មានបទពិសោធន៍យ៉ាងតិច ២ឆ្នាំទាក់ទងនឹងការបង្កើតប្រព័ន្ធតាមដាននិងវាយតំលៃគម្រោង
- មានបទពិសោធន៍គ្រប់គ្រាន់ក្នុងការស្រាវជ្រាវតាមបែបការចូលរួម
- មានបទពិសោធន៍ក្នុងការប្រមូលព័ត៌មាន វិភាគ និងសរសេររបាយការណ៍
- មានបទពិសោធន៍ក្នុងការគ្រប់គ្រងគម្រោង

## ៩. ឯកសារភ្ជាប់ជាមួយៈ

- លិខិតចំណាប់អារម្មណ៍ ចំនួន០១ច្បាប់
- គម្រោងសំណើសង្ខេប ចំនួន០១ច្បាប់

- ប្រវត្តិរូបសង្ខេប ចំនួន០១ច្បាប់
- របាយការណ៍វាយតម្លៃកន្លងទៅ ចំនួន០១។
- តារាងផែនការ ចំនួន១ច្បាប់។